

# វេទិកាជាតលើកទី ២ ស្តីពីការប្រែប្រួលអាកាសធាតុ
# ព្រះរាជាណាចក្រកម្ពុជា
# ថ្ងៃទី០៣-០៥ ខែតុលា ឆ្នាំ២០១១

## សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា


លោក ស៊ុំ ធី

ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជាអ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ
នៃគម្រោងគ្រប់គ្រងចំណេះដឹង និងអភិវឌ្ឍន៍គោលនយោបាយប្រែប្រួលអាកាសធាតុ
ក្រសួងបរិស្ថាន

# មាតិកា នៃបទបង្ហាញ

- បទបង្ហាញនេះនឹងធ្វើការពិពណ៌នាអំពីគោលបំណង សកម្មភាពសំខាន់ៗ ការចម្រើន និងជំហានបន្ទាប់ នៃ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)

## • គោលបំណង

- ធ្វើការបង្ហាញជូន នូវទិដ្ឋភាពទូទៅរបស់ CCCA

# សេចក្តីផ្តើម

- CCCA គឺជាគំនិតផ្តួចផ្តើមរបស់ពហុម្ចាស់ជំនួយ ដែលមានវិធានមូលនិធិ បែបផ្អែប្រឌិត និងទូលំទូលាយ ក្នុងការឆ្លើយតបនឹងការបន្សុំា និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ
  - សម្ព័ន្ធភាពនេះកើតឡើងពីគំនិតផ្តួចផ្តើមរបស់សហព័ន្ធអឺរ៉ុប ក្នុងការបង្កើត នូវសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ ដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍តិចបំផុត និងប្រទេសកោះតូចៗ ក្នុងការឆ្លើយតបនឹងការបន្សុំា និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- UNDP ធ្វើការគ្រប់គ្រងមូលនិធិ CCCA ជាបណ្តោះអាសន្ន ហើយនឹងធ្វើការផ្ទេរជាបណ្តើរៗ រហូតដល់ពេលរដ្ឋាភិបាលអាចគ្រប់គ្រង និងភាពជាម្ចាស់ការពេញលេញ
  - រយៈពេល៖ ៣ ឆ្នាំ (២០១០-២០១២)
  - ថវិកា៖ ៨.៩ ដុល្លារសហរដ្ឋអាមេរិច ឧបត្ថម្ភដោយ Sida, DANIDA និង UNDP
  - អនុវត្តដោយ៖ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន តាងនាមអោយគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC)
  - CCCA ជាសេនាធិការរបស់ NCCC ក្នុងការដឹកនាំ លើចំណោះដឹង និងគោលនយោបាយប្រែប្រួលអាកាសធាតុ

# គោលបំណង និងផ្នែកសំខាន់របស់ CCCA

**គោលបំណងទូទៅ៖** សកម្មភាពប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកម្ពុជាគឺជាការងារជាតិ ដឹកនាំ និងអនុវត្តស្របតាមអាទិភាពអភិវឌ្ឍន៍ជាតិ ហើយសកម្មភាពទាំងនេះមានការសម្របសម្រួល និងអនុវត្តប្រកបដោយប្រសិទ្ធភាព

## ផ្នែក/លទ្ធផលសំខាន់ៗ

- **លទ្ធផល ១៖** ពង្រឹងសមត្ថភាពរបស់ NCCC ក្នុងការសម្របសម្រួលបង្កើតគោលនយោបាយ អភិវឌ្ឍន៍សមត្ថភាព និងការធ្វើប្រជាមតិ/ផ្សព្វផ្សាយ និងធ្វើការតាមដានការអនុវត្តយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុថ្នាក់ជាតិ
- **លទ្ធផល ២៖** លើកកម្ពស់ការទទួលបានព័ត៌មានប្រែប្រួលអាកាសធាតុ ដែលមានបច្ចុប្បន្នភាព ផ្តល់ឱកាសសិក្សារៀនសូត្រ និងទទួលបានចំណេះដឹងនៅគ្រប់កម្រិត
- **លទ្ធផល ៣៖** គ្រប់គ្រងមូលនិធិ (រួមមានជំនួយឥតសំណងរបស់គម្រោង) និងធ្វើការងារជាមួយនឹងរចនាសម្ព័ន្ធរបស់ មូលនិធិ នាពេលអនាគត

# សកម្មភាពសំខាន់ៗ

- ដើម្បីសម្រេចបាន នូវគោលបំណងសំខាន់ៗរបស់ CCCA ក្នុងការគាំទ្រដល់ការពង្រឹងស្ថាប័ន និងអភិវឌ្ឍសមត្ថភាពការប្រែប្រួលអាកាសធាតុរបស់រាជរដ្ឋាភិបាល CCCA
  - បង្កើត នូវផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា សម្រាប់ធ្វើជាក្របខ័ណ្ឌក្នុងការអភិវឌ្ឍគោលនយោបាយប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបការប្រែប្រួលអាកាសតាមបណ្តាវិស័យ
  - អភិវឌ្ឍយន្តការ និងសម្ភារៈ ដើម្បីលើកកម្ពស់ចំណេះដឹង ការយល់ឃើញ និងការចែករំលែកព័ត៌មានប្រែប្រួលអាកាសធាតុនៅគ្រប់កម្រិត
  - ផ្តល់ នូវជំនួយឥតសំណងដល់គម្រោងកសាងសមត្ថភាពប្រែប្រួលអាកាសធាតុ នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ
  - ធ្វើការពង្រឹងសមត្ថភាព និងលទ្ធភាពចរចារ លើការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា ដើម្បីអនុវត្តឲ្យបាន នូវកាតព្វកិច្ចខ្លួន ចំពោះ UNFCCC
  - ធ្វើការលើកកម្ពស់ភាពធន់ទ្រាំ និងជីវភាពរបស់សហគមន៍តំបន់ឆ្នេរ និងការការពារ/ការស្តារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ

# ការរីកចម្រើន

លទ្ធផល ១៖

- បង្កើត នូវក្រុមបច្ចេកទេសប្រែប្រួលអាកាសធាតុ ដោយមានសមាជិក ចំនួន ១៦នាក់ មកពីក្រសួង និងស្ថាប័ន NCCC ចំនួន ១៣
- រៀបចំកិច្ចប្រជុំត្រៀម សម្រាប់ COP 16 ជាមួយបណ្តាក្រសួងរដ្ឋាភិបាល និង CSOs បានរៀបចំដោយ CCD ក្នុងខែវិច្ឆិកា ឆ្នាំ២០១០
- ធ្វើការគាំទ្រដល់ការចូលរួមថ្នាក់ជាតិ ក្នុងកិច្ចប្រជុំចរចារ លើការប្រែប្រួលអាកាសធាតុ និង COP 17 នាពេលខាងមុខ
- សិក្ខាសាលាផ្សព្វផ្សាយ COP 16 បានប្រារព្ធឡើង ក្នុងខែមីនា ឆ្នាំ២០១១
- ផលិត នូវឯកសារទស្សនទាន និងផែនទីបង្ហាញផ្លូវ នៃផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា

# ការរីកចម្រើន

**លទ្ធផល ២៖**

- រៀបចំ និងសម្ភោធរបាយការណ៍ KAP (ចំណេះដឹង ឥរិយាបទ និងការអនុវត្ត)
- រៀបចំយុទ្ធសាស្រ្តព័ត៌មានជាសាធារណៈ ស្តីពីការប្រែប្រួលអាកាសធាតុ
- បានផ្សព្វផ្សាយការជជែកពិភាក្សា អំពីការប្រែប្រួលអាកាសធាតុតាមកញ្ចក់ទូរទស្សន៍ CTN
- បានផ្តល់យោបល់យ៉ាងច្រើន លើរបាយការណ៍អភិវឌ្ឍន៍មនុស្សជាតិ របស់ប្រទេសកម្ពុជា និងបានរៀបចំកិច្ចប្រជុំបច្ចេកទេស និងធ្វើការសម្ភោធ
- ធ្វើជាម្ចាស់ និងរៀបចំវេទិកាការប្រែប្រួលអាកាសធាតុថ្នាក់ជាតិលើកទី ២
- បង្កើតការឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេសដល់អ្នកពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ

# ការរីកចម្រើន

**លទ្ធផល ៣៖**

- ការអំពាវនាវឲ្យដាក់ពាក្យស្នើសុំលើកទី ១ របស់មូលនិធិ CCCA បានបើក នៅចុងខែកុម្ភៈ
- មានអ្នកដាក់ពាក្យ ពី ១០នាក់ ដល់ ៦០ បានទទួលការអញ្ជើញឲ្យដាក់បញ្ជូនសំណើពេញលេញ
- សំណើគម្រោងចំនួន ១០ បានទទួលការអនុញ្ញាតដោយមានជាប់លក្ខខណ្ឌ ពី PSB និងមានការផ្តល់ពេលវេលាបន្ថែមរយៈពេល ១ខែ ក្នុងការបំពេញភាពខ្វះចន្លោះ ដែលនៅសេសសល់។ ការផ្តល់ថវិកាជាបណ្តោះអាសន្ន សម្រាប់គម្រោងថ្មីមានរហូតដល់ ២.២ លានដុល្លារសហរដ្ឋអាមេរិច
- ការជ្រើសរើសជាចុងក្រោយ នៃគម្រោង នៅដើមខែសីហា នឹងបន្តដោយការវាយតម្លៃសមត្ថភាព និងការចុះកិច្ចសន្យា
- ការអនុម័ត នូវសៀវភៅណែនាំ សម្រាប់ប្រតិបត្តិការមូលនិធិ CCCA

# ជំហានបន្ទាប់

- បង្កើត នូវផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុកម្ពុជា ដោយមានការប្រឹក្សាយោបល់ និងវាយតម្លៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមបណ្តាក្រសួង
- ការអំពាវនាវឲ្យមានការដាក់សំណើដំណាក់កាលបន្ទាប់ គឺគ្រោងធ្វើឡើងនៅចុងឆ្នាំ ២០១១
- រៀបចំការវាយតម្លៃសមត្ថភាពការប្រែប្រួលអាកាសធាតុរបស់ CCD និង NCCC
- បង្កើនការចូលរួម ក្នុងគ្រោងការអន្តរវិស័យ និងសមភាពយេនឌ័រ ការកាត់បន្ថយហានិភ័យចំពោះគ្រោះមហន្តរាយ និងការយល់ដឹង
- បង្កើត នូវផែនការសកម្មភាព និងយុទ្ធសាស្រ្តចំណេះដឹង និងការអប់រំ
- អភិវឌ្ឍផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុ ដើម្បីពង្រឹងការបញ្ជ្រាបការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ទៅក្នុងក្របខ័ណ្ឌមួយកាន់តែទូលំទូលាយ ក្នុងរបៀបវារៈ នៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា
- COP 17 (វិច្ឆិកា - ធ្នូ) ក្នុងអាហ្វ្រិកខាងត្បូង


សូមអរគុណ !
For more information:
*www.camclimate.org.kh*